**មាត្រា ៤ :** សមាជិកទាំងអស់ ព្រមទាំងក្រុមជំនួយការរបស់ក្រុមប្រឹក្សាអ្នកច្បាប់ ត្រូវចូលរួមធ្វើការងារ និង ប្រជុំតាមការអញ្ជើញរបស់សហប្រធាន ។

**មាត្រា ៥ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង ឯកឧត្តមអស់លោក ដែលមាននាមក្នុងមាត្រា ១ និង មាត្រា ៣ មានភារកិច្ចអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ១៤ អនក្រ
## ស្តីពីការបែងចែកខ្ទង់ចំណាយឥណទានធុក

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាយអោយប្រើដោយព្រះរាជក្រមលេខ ០២ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីការបែងចែកឥណទាន តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១ :** ផ្តល់ឥណទានបន្ថែម ដោយយកចេញពីជំពូក ៤១ " ចំណាយឥតគ្រោងទុក " នៃថវិការដ្ឋជូនទៅស្ថាប័នក្រសួងទាំងឡាយ ដូចខាងក្រោមនេះ។

**រដ្ឋសភា**

ជំពូក ១១ :.................................................. ២០០លានរៀល

ទីស្តីការគណៈរដ្ឋមន្ត្រី ផ្នែកទី ១ _ទីស្តីការគណៈរដ្ឋមន្ត្រី

ជំពូក ៥១ :.................................................. ៨.៥៥០លានរៀល

ក្រសួងមហាផ្ទៃ ផ្នែកទី ២ _រដ្ឋបាលទូទៅ

ជំពូក ១០ :.................................................. ៥៧០ លានរៀល

ជំពូក ១២ :.................................................. ៣៥០ លានរៀល

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ជំពូក ១០ :.................................................. ៧០ លានរៀល

ជំពូក ១២ :.................................................. ២.៧៥០ លានរៀល

ជំពូក ៣២ :.................................................. ១.២៥០ លានរៀល

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ជំពូក ១១ :.................................................. ៥០ លានរៀល

ជំពូក ៣០ :.................................................. ៥០០ លានរៀល

ក្រសួងអប់រំយុវជន និង កីឡា ផ្នែកទី ១ _អប់រំ

ជំ[illegible] :.................................................. ១១.០០០ លានរៀល

ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

ជំពូក ៣០ :.................................................. ១.៦២០ លានរៀល

ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

ជំពូក ៣១ :.................................................. ២.០៤០ លានរៀល

**មាត្រា ២ ៖** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

***

*រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិនា ឆ្នាំ ១៩៩៤*

# អនុក្រឹត្យលេខ ២១ អនក្រ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែវិច្ឆិកាឆ្នាំ ១៩៩៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- ពិនិត្យសំណូមពរការងារ និង សមត្ថភាពរបស់មន្ត្រីរាជការ
- តាមសំណើរដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា

## សំរេច

**មាត្រា ១ ៖** ត្រូវបានតែងតាំងលោក **យី ធន់** ជាទីប្រឹក្សាអមក្រសួងធម្មការ និង សាសនា។

**មាត្រា ២ ៖** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងធម្មការ និងសាសនា រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងលោក **យី ធន់** ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**